# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

## កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2016
## (**សេដ្ឋកិច្ច ក្រុមទី៧៖ ថាមពល**)

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧

តាមការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន យុវជនកម្ពុជាចំនួន២៣រូប នឹងធ្វើទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី៧ ខែមីនា ជាមួយក្រុមយុវជនមកពីបណ្តាប្រទេសអាស៊ាន ទីម័រខាងកើត និងប្រទេសឥណ្ឌា ក្រោមកម្មវិធីបណ្តាញផ្លាស់ប្តូរសិស្ស និស្សិត និងយុវជន រវាងប្រទេសជប៉ុន និងបណ្តាប្រទេសអាស៊ីខាងកើត ដែលហៅកាត់ថា JENESYS 2016។

ក្រោយពីធ្វើទស្សនិច្ចនៅទីក្រុងតូក្យូ ក្រុមយុវជននឹងបន្តធ្វើទស្សនកិច្ចទៅកាន់ខេត្តអាគីតា ដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរជាមួយ ស្ថាប័ននានា និងបណ្តាក្រុមហ៊ុនឯកជន ក្រោមប្រធានបទ ″**ថាមពល**″។ ពួកគេក៏នឹងមានឱកាសទទួលបទពិសោធន៍ស្នាក់នៅជាមួយគ្រួសារជនជាតិជប៉ុនផងដែរ។ កម្មវិធីលម្អិតមានភ្ជាប់ជាមួយសេចក្តីប្រកាសព័ត៌មាននេះ។

កម្មវិធី JENESYS 2016 មានគោលបំណងជម្រុញការយល់ដឹង និងការកសាងទំនុកចិត្តទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និងបណ្តាប្រទេសចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។ តាមរយៈកម្មវិធីនេះក្រសួងការបរទេសបានអញ្ជើញយុវជនកម្ពុជាចំនួនជាង២០០០នាក់ហើយ តាំងពីឆ្នាំ២០០៧មក។

យើងខ្ញុំសង្ឃឹមថាអ្នកចូលរួម នឹងអាចយល់ដឹងអំពីប្រទេសជប៉ុនកាន់តែស៊ីជ្រៅថែមទៀត ព្រមទាំងចែករំលែកនូវបទពិសោធរបស់ពួកគេទៅកាន់ប្រជាជនកម្ពុជា បន្ទាប់ពីពួកគេវិលត្រលប់មកវិញ។

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161, Fax: 023 216 162*
*Email: info.jpn@pp.mofa.go.jp*
*Official Website: www.kh.emb-japan.go.jp*